ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ

លេខ ៤៤១ សក ក្រច

ក្រចេះ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៧

## សេចក្តីណែនាំ

## ស្តីពីសុវត្ថិភាពតាមផ្លូវទឹក នារដូវទឹកជំនន់ឆ្នាំ ២០១៧

មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ មានកិត្តិយសសូមជម្រាបដល់ម្ចាស់ជលយាន ជលយានយន្ត និងម្ចាស់អាជីវកម្មដចម្លងទាំងអស់ដែលធ្វើចរាចរណ៍តាមផ្លូវទឹក ដូចជា៖ ទន្លេ បឹង ព្រែក ឱ្យបានជ្រាបថា: ដោយសង្កេតឃើញក្នុងរដូវវស្សាឆ្នាំ ២០១៧ នេះ អាកាសធាតុមានការប្រែប្រួលខ្លាំង បណ្តាលឱ្យមានខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ខ្យល់ជំនោររលកធំៗ តាមដងទន្លេ និងមានភ្លៀងធ្លាក់ច្រើននៅអាងទន្លេមេគង្គ ធ្វើឱ្យកំពស់ទឹកទន្លេមេគង្គហក់ឡើងជាបន្តបន្ទាប់ ។ ដូចនេះ ដើម្បីធានាសុវត្ថិភាព សណ្តាប់ធ្នាប់ចរាចរណ៍ផ្លូវទឹក អនាម័យ និងការពារអាយុជីវិតអ្នកដំណើរ ទ្រព្យសម្បត្តិ មធ្យោបាយដឹកជញ្ជូនផ្លូវទឹក មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះសូមធ្វើការណែនាំដូចតទៅ៖

១- គ្រប់ជលយាន ជលយានយន្ត ពេលធ្វើចរាចរណ៍ឆ្លងកាត់ទន្លេ បឹង ព្រែក ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច ដោយត្រូវពិនិត្យមើលផ្ទៃមេឃ ចរន្តទឹករលក ខ្យល់បក់ ឬទឹកជំនន់ មុននឹងឆ្លងកាត់ ។ ក្នុងករណី មានខ្យល់បក់បោកខ្លាំង រលកធំៗ ភ្លៀងធ្លាក់ខ្លាំង ត្រូវផ្អាកការចម្លង ឬធ្វើដំណើរឆ្លងកាត់ជាបណ្តោះអាសន្ន ។

២- គ្រប់ជលយាន ជលយានយន្ត ត្រូវមានឧបករណ៍សង្គ្រោះ ដូចជា៖ អាវពោង ពោងសុវត្ថិភាព ភ្លើងបំភ្លឺនៅពេលធ្វើចរាចរណ៍ពេលយប់ ឧបករណ៍បំពងសំលេង ប្រព័ន្ធទាក់ទង ប្រដាប់ពន្លត់ភ្លើង ម៉ាស៊ីនបូមទឹក ពិសេស ម៉ាស៊ីនដែលជាមធ្យោបាយអូសទាញជលយាន ជលយានយន្ត ដែលធានាមិនឱ្យខូចពេលកំពុងធ្វើចរាចរណ៍ សម្រាប់ការពារនៅពេលមានគ្រោះថ្នាក់ជាយថាហេតុ ។

៣- ដចម្លង ត្រូវធ្វើការថែទាំផ្លូវចូលកំពង់ និងផ្លូវទេរចុះឡើង ដោយត្រូវមានកំណល់ទុកសម្រាប់កល់រថយន្ត និងមានកម្មករជួយទប់ពេលទោចក្រយានយន្ត ត្រីចក្រយានយន្ត ចុះឡើងផ្លូវទេរ ដើម្បីជៀសវាងការគ្រោះថ្នាក់បណ្តាលមកពីរអិលជាយថាហេតុ ។

៤- ត្រូវផ្ទុកឱ្យបានត្រឹមត្រូវតាមច្បាប់អាជីវកម្មដឹកជញ្ជូន ដោយមិនត្រូវផ្ទុកហួសចំណុះ ហើយចំពោះ ជលយានយន្តដែលពុំទាន់បំពេញបែបបទច្បាប់អាជីវកម្មដឹកជញ្ជូន និងសៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេស ឬផុតកំណត់ ត្រូវមកបំពេញបែបបទ ឬបន្តសុពលភាពនៅមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ ។

តាមបណ្តោយផ្លូវជាតិលេខ 73 ក្នុងសង្កាត់ក្រចេះ ក្រុងក្រចេះ Phone&Telegram 012 57 82 54 Email.pw_krt@yahoo.com

៥- ហាមចាក់កាកសំណល់ ដូចជា៖ សំរាម បង្ហូរប្រេងម៉ាស៊ីនចូលទន្លេ បឹង ព្រែក ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តក្រចេះ សង្ឃឹមយ៉ាងមុតមាំថាៈ បងប្អូនប្រជាពលរដ្ឋដែលជាម្ចាស់ជលយាន ជលយានយន្ត ម្ចាស់ដចម្លងទាំងអស់ពិតជាចូលរួមអនុវត្តដោយស្មារតីប្រុងប្រយ័ត្ន និងភ្ញាក់រលឹកខ្ពស់ ។

**ប្រធានមន្ទីរ**

**នូ សុវណ្ណា**

**ចម្លងជូនៈ**

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ឯកឧត្តម ប្រធានក្រុមប្រឹក្សាខេត្ត
- សាលាខេត្តក្រចេះ
- ស្នងការដ្ឋាននគរបាលខេត្ត
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត
- សាលាក្រុងស្រុកទាំង ៦

(ដើម្បីគោរពជូនជ្រាប)

- បណ្តាញសារព័ត៌មានខេត្ត

(ដើម្បីជួយផ្សព្វផ្សាយ)

- ឯកសារ កាលប្បវត្តិ

តាមបណ្តោយផ្លូវជាតិលេខ 73 ក្នុងសង្កាត់ក្រចេះ ក្រុងក្រចេះ Phone&Telegram 012 57 82 54 Email.pw_krt@yahoo.com